ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខៈ ៤០៣០ ប្រក

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រការ២ នៃប្រកាសលេខ ២១៧៥ ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- អនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរវិម្ហាការអំណាច តួនាទី ភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- យោងតាមការចាំបាច់

## សម្រេច

**ប្រការមួយ.-**

ប្រការ២ នៃប្រកាសលេខ ២១៧៥ ប្រក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ស្តីពីក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត ត្រូវបានកែសម្រួលដូចខាងក្រោម៖

**ប្រការ ២.- ថ្មី**

ក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្តនីមួយៗ មានចំនួនចាប់ពី ០២ (ពីរ)រូប ទៅដល់ ០៤ (បួន)រូប អាស្រ័យទៅតាមកត្តាប្រជាសាស្ត្រ ភូមិសាស្ត្រ ទំហំការងារ និងតម្រូវការសេវាផ្លូវច្បាប់ នៃរដ្ឋបាលរាជធានី ខេត្តនីមួយៗ ដូចបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធ(ថ្មី) ដែលភ្ជាប់ជាមួយប្រកាសនេះ។ ក្រសួងមហាផ្ទៃអាចធ្វើការកែសម្រួលចំនួនក្រុមមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត តាមការចាំបាច់។ ការទទួលស្គាល់មេធាវីឱ្យបំពេញការងារតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**ប្រការពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការបី.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រុមប្រឹក្សានីតិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អង្គភាពផ្សេងទៀតចំណុះក្រសួងមហាផ្ទៃ ក្រុមប្រឹក្សារាជធានី ខេត្ត និងគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ទង្គារ ១១ កើត ខែ ភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**តារាងឧបសម្ព័ន្ធ ភ្ជាប់នឹងប្រកាសលេខ ៥០៣០ ប្រក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០២២**
**ស្តីពីការកែសម្រួលចំនួនមេធាវីប្រចាំរដ្ឋបាលរាជធានី ខេត្ត**

| ល.រ | រាជធានី ខេត្ត | ចំនួនមេធាវី |
|---|---|---|
| ១ | រាជធានីភ្នំពេញ | ០៤ រូប |
| ២ | ខេត្តបាត់ដំបង | ០៤ រូប |
| ៣ | ខេត្តកណ្តាល | ០៤ រូប |
| ៤ | ខេត្តព្រៃវែង | ០៤ រូប |
| ៥ | ខេត្តកំពង់ចាម | ០៤ រូប |
| ៦ | ខេត្តកំពង់ធំ | ០៤ រូប |
| ៧ | ខេត្តសៀមរាប | ០៤ រូប |
| ៨ | ខេត្តត្បូងឃ្មុំ | ០៤ រូប |
| ៩ | ខេត្តព្រះសីហនុ | ០៤ រូប |
| ១០ | ខេត្តកំពង់ស្ពឺ | ០៤ រូប |
| ១១ | ខេត្តតាកែវ | ០៣ រូប |
| ១២ | ខេត្តបន្ទាយមានជ័យ | ០៣ រូប |
| ១៣ | ខេត្តកំពត | ០៣ រូប |
| ១៤ | ខេត្តស្វាយរៀង | ០៣ រូប |
| ១៥ | ខេត្តកំពង់ឆ្នាំង | ០៣ រូប |
| ១៦ | ខេត្តកោះកុង | ០៣ រូប |
| ១៧ | ខេត្តមណ្ឌលគិរី | ០៣ រូប |
| ១៨ | ខេត្តពោធិ៍សាត់ | ០៣ រូប |
| ១៩ | ខេត្តក្រចេះ | ០២ រូប |
| ២០ | ខេត្តប៉ៃលិន | ០២ រូប |
| ២១ | ខេត្តព្រះវិហារ | ០២ រូប |
| ២២ | ខេត្តរតនគិរី | ០២ រូប |
| ២៣ | ខេត្តស្ទឹងត្រែង | ០២ រូប |
| ២៤ | ខេត្តកែប | ០២ រូប |
| ២៥ | ខេត្តឧត្តរមានជ័យ | ០២ រូប |